អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់ សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងសំណុំរឿង ០០៣

យោងតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់ អវតក សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង សូមធ្វើសេចក្តីប្រកាសជាសាធារណៈ ចំពោះជំហររបស់ខ្លួនទាក់ទងទៅនឹងសំណុំរឿងលេខ ០០៣ ដូចខាងក្រោម៖

តាំងពីដំបូងនៃលទ្ធផលដែលបានស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងរហូតមកដល់ពេលនេះ ក្រោយពេលស៊ើបសួរ រហូតដល់ការបិទការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាជាតិ បានពិនិត្យ និងមានជំហរយ៉ាងច្បាស់ថា ជនសង្ស័យដែលមានឈ្មោះនៅក្នុងសំណុំរឿងលេខ ០០៣ មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

យោងតាមស្មារតីនៃ ច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក និងបុព្វកថានៃកិច្ចព្រមព្រៀងចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ដែលមហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ នោះ បានតម្រូវឲ្យសហព្រះរាជអាជ្ញា ជ្រើសរើសយកជនតែពីរប្រភេទប៉ុណ្ណោះមកធ្វើការកាត់សេចក្តី ពោលគឺ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេស



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

កម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

ម្យ៉ាងទៀត សហព្រះរាជអាជ្ញាជាតិយល់ថា គួរតែផ្តល់អាទិភាពទៅលើការវិនិច្ឆ័យទោសជនជាប់ចោទដែលកំពុងតែជាប់ឃុំនៅ អ.វ.ត.ក។ តាមខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និង ច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក បានគិតទុកជាមុនអំពីការវិនិច្ឆ័យទោសចំពោះមនុស្សមួយចំនួនតូចប៉ុណ្ណោះ។

ហេតុដូច្នេះ សហព្រះរាជអាជ្ញាជាតិ ប្រកាន់ជំហរថា ជនសង្ស័យដែលមានឈ្មោះនៅក្នុងសំណុំរឿងលេខ ០០៣ មិនស្ថិតនៅក្នុងយុត្តាធិការ របស់ អ.វ.ត.ក ដែលត្រូវយកមកធ្វើការកាត់សេចក្តីឡើយ ហើយការកាត់សេចក្តីទៅលើជនជាប់ចោទដែលកំពុងតែជាប់ឃុំនៅ អ.វ.ត.ក គឺជាការបំពេញបានយ៉ាងគ្រប់គ្រាន់ចំពោះអាណត្តិរបស់តុលាការនេះ។



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh